២២ មិថុនា ២០២៤

# សេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំកំពូលប្រចាំអាស៊ីអាគ្នេយ៍ស្តីពីបណ្តាញសិទ្ធិអ្នកនេសាទរបស់សហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូនអន្តរជាតិអាយធីអេហ្វ

បណ្តាញសិទ្ធិអ្នកនេសាទរបស់សហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូនអន្តរជាតិ (អាយធីអេហ្វ-អេហ្វអាអិន) កំពុងបង្កើតចលនាអ្នកនេសាទក្នុងតំបន់ដើម្បីលុបបំបាត់ការកេងប្រវ័ញ្ចនិងលើកកំពស់ស្តង់ដារឧស្សាហកម្មព្រោះអ្នកនេសាទទាំងអស់ក្នុងអាស៊ីអាគ្នេយ៍សាកសមនិងទទួលបានការគោរព និងភាពយុត្តិធម៌។ ការព្រួយបារម្ភដល់សំខាន់របស់ពួកយើងមិនទទួលបានការដោះស្រាយពីខាងរដ្ឋាភិបាលព្រមទាំងធ្វើអោយពួកយើងនៅតែទទួលបានការរំលោភបំពានសិទ្ធិពីចៅហ្វាយរបស់ពួកយើង។ នេះហើយជាហេតុផលដែលពួកយើងកំពុងបង្កើតសហជីពមួយនេះដើម្បីការពារខ្លួនឯងក្នុងនាមជាអ្នកនេសាទនិងតស៊ូដើម្បីភាពយុត្តិធម៌សម្រាប់អ្នកនេសាទទាំងអស់គ្នា។

**ពួកយើងទាមទារអោយមាន:**

- ការអនុម័តនិងការអនុវត្តយ៉ាងមានប្រសិទ្ធិភាពរបស់អនុសញ្ញាអង្គការពលកម្មអន្តរជាតិ ស៊ី១៨៨ (ILO C188) ពីប្រទេសទាំងអស់ទូទាំងតំបន់ដើម្បីធានានូវការការពារយ៉ាងគ្រប់ជ្រុងជ្រោយសម្រាប់អ្នកនេសាទរួមទាំងលក្ខខណ្ឌការងារសមរម្យ ប្រាក់ឈ្នួលសមរម្យ សុខភាព និងសុវត្ថិភាពការងារ និងអត្ថប្រយោជន៍សន្តិសុខសង្គម។
- ការការពារសិទ្ធិរបស់អ្នកនេសាទអោយមានសិទ្ធិសេរីភាពក្នុងការបង្កើតសមាគមនិងការចរចាជារួមដោយប្រទេសទាំងអស់នៅក្នុងតំបន់ដែលបានអនុម័តលើអនុសញ្ញាអង្គការពលកម្មអន្តរជាតិ ស៊ី៨៧ និង ស៊ី៩៨ (ILO C87/98) ព្រមទាំងផ្តល់សិទ្ធិអំណាចដល់អ្នកនេសាទក្នុងការចរចាសម្រាប់ការមើលថែយ៉ាងស្មើភាព ប្រាក់ឈ្នួលល្អប្រសើរ និងលក្ខខណ្ឌការងារ និងជីវភាពសមរម្យ។
- ការចូលប្រើប្រាស់វ៉ាយហ្វាយយ៉ាងចាំបាច់ដោយឥតគិតថ្លៃនៅលើនាវានេសាទទាំងអស់ និងសិទ្ធិសេរីភាពដែលគ្មានឧបសគ្គក្នុងការប្រើប្រាស់វ៉ាយហ្វាយដោយមិនមានការឃ្លាំមើលពីខាងក្រៅ។
- លុបបំបាត់នូវការគាបសង្កត់ក្នុងការដាក់ពាក្យការងារនិងប្រព័ន្ធកម្រៃជើងសារទូទាំងតំបន់ ដោយធានាថាអ្នកនេសាទនិងមិនត្រូវបានគេដាក់បញ្ចូលទៅក្នុងមុខតំណែងដែលជាប់បំណុល។
- ការពង្រីកបណ្តាញសិទ្ធិអ្នកនេសាទទៅកាន់ប្រទេសផ្សេងៗក្នុងតំបន់។
- ការអនុម័ត និងការផ្សព្វផ្សាយគំរូនៃកិច្ចព្រមព្រៀងចរចារួមរបស់សហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូនអន្តរជាតិ (CBA) ដើម្បីធានាសិទ្ធិនិងការការពារស្តង់ដារសម្រាប់អ្នកនេសាទទាំងអស់ ដោយមិនគិតពីសញ្ជាតិ ឬទីតាំង។
- ការសម្របសម្រួលនៃយុទ្ធនាការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីពង្រីក និងពង្រឹងសាមគ្គីភាពអ្នកនេសាទទូទាំងតំបន់។
- ការពង្រឹងភាពជាដៃគូសង្គមជាមួយសហជីព អង្គការក្រៅរដ្ឋាភិបាល អង្គការសង្គមស៊ីវិល អ្នកនយោបាយ រដ្ឋាភិបាល និងអធិការ ដើម្បីបង្កើនការគាំទ្រ និងការតស៊ូមតិសម្រាប់អ្នកនេសាទ។
- ការធ្វើសមកាលកម្មនៃថ្ងៃនៃសកម្មភាពក្នុងតំបន់ ដូចជាទិវាសិទ្ធិមនុស្សអន្តរជាតិ ទិវាអ្នកនេសាទអន្តរជាតិ ទិវានេសាទ ទិវាអ្នកនេសាទ និងទិវាសមុទ្រពិភពលោក ដើម្បីពង្រីកកិច្ចខិតខំប្រឹងប្រែងតស៊ូមតិ និងពង្រឹងសកម្មភាពរួមនៅទូទាំងតំបន់។
- ការកំណត់អត្តសញ្ញាណគោលដៅរបស់ទីភ្នាក់ងារសំខាន់ៗ ដូចជាទីប្រឹក្សា ស្ថានទូត និងទីភ្នាក់ងាររដ្ឋាភិបាល ដើម្បីជួយក្នុងដំណើរការសំណុំរឿង និងការអនុវត្តច្បាប់
- ការដាក់បញ្ចូលសំណើរការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពរបស់អង្គការសិទ្ធិមនុស្ស (HRDD) នៅក្នុងកិច្ចព្រមព្រៀង និងគោលនយោបាយខ្សែសង្វាក់ផ្គត់ផ្គង់អាហារសមុទ្រ
- ការលុបបំបាត់ពលកម្មដោយបង្ខំ ពលកម្មកុមារ ការជួញដូរមនុស្ស និងទាសភាពសម័យទំនើប (ទាសភាពសម័យទំនើប ជាស្ថានភាពនៃការកេងប្រវ័ញ្ច ដែលបុគ្គលម្នាក់មិនអាចបដិសេធ ឬចាកចេញដោយសារតែការគំរាមកំហែង អំពើហិង្សា ការបង្ខិតបង្ខំ ការបោកប្រាស់ ឬការរំលោភបំពានអំណាច)


**Contact Us:**

frncoordinator.itf@gmail.com

justiceforfishers.org

@justice4fishers

Facebook